Received by NSD/FARA Registration Unit 10/09/2024 2:08:06 PM

លោកជំទាវបណ្ឌិតសភាចារ្យ មានប្រសាសន៍បន្ថែមទៀតថា "ការបញ្ជូនត្រឡប់មកវិញនូវសម្បត្តិវប្បធម៌ជាតិនេះ បង្ហាញជាថ្មីម្តងទៀតនូវការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការបន្តស្វែងរក និងនាំយកមកវិញនូវដួងព្រលឹងដូនតារបស់យើង ដែលបានឃ្លាតចាកឆ្ងាញពីដែនដីកំណើតរបស់ខ្លួន។ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិត និងបាននាំមកនូវសន្តិភាពជូនកម្ពុជាតាមរយៈនយោបាយ ឈ្នះ-ឈ្នះ និងសូមស្វាគមន៍ការវិលត្រឡប់មកវិញនៃព្រលឹងដូនតា ដែលជាមង្គលរបស់ជាតិ ក៏ដូចជាការប្រោះព្រំប្រសិទ្ធពរជូន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីថ្មីរបស់យើង"។

លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការ និងការខិតខំប្រឹងប្រែងរបស់រដ្ឋអាជ្ញាសហរដ្ឋអាមេរិក លោក Damian Williams ការិយាល័យរដ្ឋអាជ្ញាប្រចាំសង្កាត់ភាគខាងត្បូងក្រុងញូវយ៉ក ពិសេសលោកស្រី Jessica Feinstein និង លោក Shiva Logarajah, ការិយាល័យស៊ើបអង្កេតសន្តិសុខមាតុភូមិ និងភ្នាក់ងារពិសេស លោក John P. Labbat ព្រមទាំងអាជ្ញាធរពាក់ព័ន្ធទាំងនៅក្រៅប្រទេស និងក្នុងប្រទេសកម្ពុជា ជាពិសេសថ្លែងអំណរគុណដល់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ និងក្រុមការងារក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

លោកជំទាវរដ្ឋមន្ត្រី បានថ្លែងអំណរគុណជាពិសេសចំពោះលោក Bradley J. Gordon នៃក្រុមហ៊ុន Edenbridge Asia និងលោក Steven Heimberg នៃក្រុមហ៊ុន Apex Advisors។ លោកទាំងពីរ ដែលជាទីប្រឹក្សាផ្នែកច្បាប់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានចំណាយពេលជាច្រើនឆ្នាំ សហការជាមួយក្រុមកាងារក្រសួង ក្នុងការចរចាទាមទារមកកម្ពុជាវិញនូវសម្បត្តិវប្បធម៌ខ្មែរ ជាពិសេស វត្ថុបុរាណខ្មែរដែលសារមន្ទីរ MET ប្រគល់មកវិញនាថ្ងៃនេះ។

លោកជំទាវក៏បានបញ្ជាក់ថា "យើងខ្ញុំមានមោទនភាពចំពោះការខិតខំប្រឹងប្រែង និងកិច្ចសហប្រតិបត្តិការរួមគ្នាជាមួយសហរដ្ឋអាមេរិក ក្នុងការស្វែងរក និងបញ្ជូនមកវិញនូវបេតិកភណ្ឌវប្បធម៌ខ្មែរ ដែលបាននាំចេញដោយខុសច្បាប់ពីកម្ពុជា។ ការបញ្ជូនត្រឡប់មកវិញនេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្តរបស់ប្រជាជនកម្ពុជា ដែលបានឆ្លងកាត់សង្គ្រាមស៊ីវិលរាប់ទសវត្សរ៍ និងរងគ្រោះដ៏ឈឺចាប់ពីសោកនាដកម្មនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហម និងជាការពង្រឹងទំនាក់ទំនងកាន់តែរឹងមាំឡើងជាមួយសហរដ្ឋអាមេរិក"។

Received by NSD/FARA Registration Unit 10/09/2024 2:08:06 PM